# វគ្គ ទាមទារបំណុលចាស់

ក្លិនពពួកថ្នាំសម្លាប់មេរោគ និងសំឡេងប៊ីបដ៏ស្ងប់ក្រៀមក្រំនៃម៉ាស៊ីនចលនាបេះដូង កំដរបរិយាកាសពេញបន្ទប់សម្រាកព្យាបាលតូចនេះ។ ច្រើនឆ្នាំហើយ ស៊ីណាន មិនដែលឮអ្នកម្ដាយហៅគេទេ។ កូនកំព្រាប៉ាម្នាក់នេះ មិនព្រមទទួលអារម្មណ៍ថាគេកំព្រាទាំងម៉ែម្នាក់ទៀតនោះឡើយ បើទោះជាគាត់លែងសម្លឹងគេ លែងអង្អែលសក់គេ ឬហៅគេក៏ដោយ។

ប្រុសស្អាតដែលខានញញឹមជាយូរមកហើយ ពេលនេះនៅឈរក្បែរគ្រែ ដូចតែគេបានធ្វើរាល់ដង។ ភ្នែកប្រុសស្អាតសម្លឹងមើលអ្នកម្ដាយដែលមានផ្ទៃមុខស្លេកស្លាំង បិទភ្នែកស្ងប់ស្ងាត់នៅក្រោមកម្រាលភួយសស្អើង។ បំពង់ខ្យល់ចេញពីមាត់គាត់បន្លឺសំឡេងយ៉ាងស្រទន់ បញ្ជាក់ថាក្រោមភាពស្ងប់ស្ងាត់នេះគាត់នៅត្រដររមានជីវិតនៅឡើយ ព្រោះកំពុងរង់ចាំអ្វីម្យ៉ាង....ការងារដ៏សំខាន់មួយ ឬយុត្តិធម៌មួយ។

«ម៉ាក់!»

ប្រុសហៅតិចៗពេលគេទាញកៅអីមកអង្គុយហើយកាន់ដៃគាត់ច្របាច់ថ្នមៗ។ គ្មានទេសំឡេងតប! សំឡេងតែមួយគត់នៅក្នុងបន្ទប់នេះ គឺចង្វាក់ថេរនៃម៉ូនីទ័របេះដូង។

ថ្គាមរបស់ស៊ីណាន បានកៀបជាប់ជាមួយកំហឹង ត្រជាក់ ជ្រៅ! ពេលគេអង្គុយលើកៅអីក្បែរគ្រែរបស់ម្ដាយដៃរបស់គេដែលគ្រើមនិងក្រៀមក្រំ បានលូកដៃទៅប៉ះម្រាមដៃស្ដើងរបស់ម្ដាយដោយថ្នមៗ។ ស្ត្រីដែលធ្លាប់ជាកម្លាំងចិត្តចុងក្រោយសម្រាប់ជីវិតរបស់គេ ជាពន្លឺដឹកនាំគេ ឥឡូវនេះគ្រាន់តែជាស្រមោលអតីតកាល កំដររាងកាយក្នុង Coma នេះតែប៉ុណ្ណោះ។ ភាពសោកសៅយ៉ាងជ្រាលជ្រៅបានបោកបក់មកលើគ្រួសារនេះ នៅពេលប្រុសហានិយាយ...៖

«ម៉ាក់! កូនចាប់បានគ្រាប់ពេជ្ររបស់ម៉ែនដា! កូនស្រីរបស់អាម្នាក់នោះ ឥឡូវនៅផ្ទះយើង! ពួកវាកំពុងតែឆីមិនបាន ដេកមិនកើតម៉ាក់!»

គេញញឹមសាហាវមួយឆ្វាច ដើម្បីបញ្ចប់ចិត្តដែលសែនភាពជូរចត់និងគំនុំប៉ុនភ្នំ។ គំនុំនេះ បានកសាងឡើងក្នុងជីវិតនៅសល់អស់ជាច្រើនឆ្នាំមកហើយ។

បុរសមាឌធំឱនមកហើយបន្ទាបសំឡេងខ្លួនឱ្យទៅជាខ្សឹបៗហាក់ដូចជាខ្លាចរំខានភាពស្ងប់ស្ងាត់នៃអ្នកមានគុណ៖

«ម៉ាក់...ដាវីននៅក្នុងដៃយើងឥឡូវនេះ»....ជាទម្លាប់ម្ដាយគេមិនឆ្លើយតបទេ តែគេនៅតែញញឹមយ៉ាងឈឺចាប់ហើយនិយាយបន្ថែម៖

«កូនស្រីតែមួយគត់.....របស់មនុស្សដែលបានបំផ្លាញគ្រួសារយើង!»

គេបន្តដូចជានិយាយជាមួយខ្លួនគេ៖

«ជីវិតរបស់នាងស្ថិត នៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ!»

ជាមួយកែវភ្នែកស្រពោន បង្កប់ភាពក្រអឺតនិងមានះ ដៃរបស់គេបន្ដឹងលើដៃម្ដាយបន្តិចឡើង ហើយប្រុសក្រឡេកមើលម្ដាយដោយសង្ឃឹមថា ពេលណាមួយ នឹងមានសញ្ញា...កន្ត្រាក់ ព្រិចភ្នែក ឬអ្វីក្ដី ដែលបញ្ជាក់ថា គាត់នៅជាមួយគេក្នុងឆាកជីវិតជូរចត់ឯកានេះ គាត់អាចឮសំណោកចំអករបស់គេ។

ប៉ុន្តែភាពស្ងប់ស្ងាត់នៅតែបន្តមាន....

«ការឈឺចាប់របស់យើង នឹងចប់! ពួកវានឹងសង! ទឹកភ្នែកយើងចប់ហើយម៉ាក់ តែខាងពួកនោះគ្រប់យ៉ាងទើបតែចាប់ផ្ដើមទេ! កូនជាព្រហ្មលិខិតរបស់ពួកវា!»

សំឡេងរបស់គេញាប់ញ័រ។

ដូចរាល់ដង គេសម្រាកស្ដាប់ដង្ហើមម្ដាយដល់អាធ្រាត្ររមលងទៅទើបចាកចេញ។ នេះជាជីវិតមួយរយៈពេលចុងក្រោយនេះ។ គេតែងតែគ្មានអ្នកណាទុកចិត្តបានហើយមានតែម៉ាក់!

ចេញមកតម្រង់រកលើឡានស្ព័រចាស់មួយ ដែលគេបានកែច្នៃដោយការសន្សំគ្រឿងបន្លាស់ ហើយទុកវាជាសម្លាញ់ចិត្តសម្រាប់បម្រើបេសកកម្មទាមទារគំនុំ ប្រុសបើកវាកំដរចិត្តសោកសៅ។

បរិវេណមន្ទីរពេទ្យមានភាពស្ងប់ស្ងាត់ខុសធម្មតាសម្រាប់ពេលយប់នេះ ដោយមានតែរថយន្តពីរបីគ្រឿងប៉ុណ្ណោះដែលចតនៅ។

សំឡេងស្រទន់តិចៗ ក្អក ក្មេងយំល្វើយៗនៃអាគារអ្នកជំងឺហាក់ដូចជាទាញចិត្តគេឱ្យនឹងនរត្រិះរិះទៅឆ្ងាយ សែនឆ្ងាយ។ ជំហានធ្ងន់ៗម៉ឺងៗរបស់គេបានបន្លឺឡើងក្នុងភាពដែលចិត្តនេះទទេឥតមនោសញ្ចេតនាសម្រាប់អ្នកណា។

តែនៅពេលដើរសំដៅដល់រថយន្តតូចទាប ដែលមិនចេះនិយាយ មានចិត្តស្មោះនឹងគេ ប្រុសញញឹមដាក់វា។

ព្រោះគេមានអារម្មណ៍ថា មាននរណាម្នាក់ដើរតាមមកពីក្រោយ។

ស៊ីណានគ្រលាស់ស្មា ហើយនឹកដល់ស្រីតូចនៅឯផ្ទះ។

ព្រះនាងអស់ឫទ្ធិនេះមានមនុស្សមកតាមយើងមែន!

គេនិយាយប្រាប់បេះដូងខ្ទេចខ្ទាំរបស់គេតិចៗហើយបង្កើនល្បឿនទាំងមាត់ញញឹមជឿជាក់។ ភ្នែករបស់គេកំពុងតែស្កេនស្រមោលមនុស្សអន្ទោល។

ចលនាមួយភ្លែតនោះ  រេទៅលាក់ខ្លួនក្បែររថយន្តJeepមួយក្នុងចំណោមរថយន្តចតមួយជួរនៅអាគារផ្សេងទៀត។ ដោយគិតថាគេមិនចាប់ភ្លឹក ឬមើលមិនឃើញនៅក្នុងពន្លឺព្រះខែស្រអាប់។

តែស៊ីណានដឹងគ្រប់យ៉ាង! សំឡេងនេះ ទីនេះ គេមកសឹកបាតជើងទៅហើយ ច្រើនឆ្នាំហើយ ឆ្នាំមួយក៏គេស្គាល់ដែរ។

«ដារីន! ពេលខ្ញុំចាត់ការមនុស្សរបស់អ្នកនាងតូចហើយ អ្នកនាងតូចនឹងត្រូវខ្ញុំចាត់ការវិញ!»

គេសន្យានឹងបេះដូងខ្លួនឯងដែលលោតញាប់ក្នុងទ្រូង ប៉ុន្តែទឹកមុខរបស់គេនៅតែស្ងប់។

ស៊ីណានខាំមាត់.....ទុក្ខវេទនាជាច្រើនឆ្នាំមកនេះ  គេមិនដែលគិតថា  គេអាចថ្ងៃណាមួយក្លាយជាមនុស្សដែលងាយនឹងស្លន់ស្លោនោះទេ។

ស្ថានភាពធ្ងន់ធ្ងរជាងនេះ គេឆ្លងកាត់អស់ហើយ!

ស៊ីណានចុចបើកទ្វារឡាន  ហើយឈានចូលក្នុងរថយន្តដោយមិនខ្វីមើលទៅក្រោយ។ គេរក្សាចលនាស្ងប់ថយឡានដោយរលូន  ប៉ុន្តែនៅក្នុងចិត្តរបស់គេ  គឺចំអកប្រណាំងនឹងគ្រួសារអភិជន។ ភ្នែករបស់ស៊ីណានងាកទៅកញ្ចក់មើលក្រោយ។ មនុស្សបីនាក់ មានមាឌធំនិងរហ័សរហួនបានខិតមកដល់យ៉ាងឆាប់រហ័ស   ច្បាស់ឡើងៗនៅពេលនេះ   ក្នុងនោះមានម្នាក់ដែលលបលាក់ប្រដាប់ដោយអាវុធខ្លីក្នុងអាវស្ត័រក្រៅ។

ស៊ីណានក្តាប់មាត់ ប្តូររថយន្តចូលក្នុងប្រអប់លេខ ហើយជាន់ឈ្នាន់បង្កើនល្បឿន។ កង់រថយន្តបានក្រឡាប់ផ្ទារជើង   ចង្កូតរេទៅមុខក្នុងល្បឿនលឿនសំដៅផ្លូវចេញ។   គេអាចឮសំឡេងស្រែកគ្រហឹមតិចៗពីក្រោយហើយបាត់ទៅវិញដោយសំឡេងគ្រហឹមនៃម៉ាស៊ីន។

គេក្រឡេកកញ្ចក់ក្រោយម្ដងទៀត អ្នកប្រដេញតាមគេបានរត់គេចឡើងឡានហ្ស៊ីប...បញ្ឆេះចាំជាស្រេច ប៉ុន្តែយឺតពេលហើយ។ ស៊ីណានបានដកខ្លួនចេញពីពេទ្យទៅតាមផ្លូវតូចចង្អៀតដែលពួកគេមិនធ្លាប់ស្គាល់។

«គ្នាវាបួននាក់!»

គេងក់ក្បាលរអ៊ូៗនិយាយតែម្នាក់ឯងទាំងអំនួតនិងចង់ប្រជែង។ ទោះយ៉ាងណា រថយន្តស្ព័រតូចរបស់គេ បានធ្វើដំណើរយ៉ាងលឿនតាមផ្លូវជឿងហែមដែលស្ងាត់គ្មានការតាមមកទាន់។ ប៉ុន្តែ... ភាពតានតឹងមិនបានចប់ងាយទេ ពេលគេចេញមកដល់ផ្លូវធំ ដឹងថាមានអ្នកមកតាមទៀត។

ឡានហ្ស៊ីបដដែល។

ល្អ!

ត្រឹម៥នាទី ស៊ីណានបានបត់ជារង្វង់ហើយបញ្ឆោតពួកគេឱ្យជាប់ក្នុងរង្វង់នៃសំណង់ផ្លូវដែលរារាំងហាមឃាត់គាំងនៅទីនោះ ទុកឱ្យខ្លួនគេបានចេញវ៉ារទៅមុន ហើយបង្កើនល្បឿនទម្លាយយប់ដ៏ស្ងាត់នៃទីក្រុងភ្នំពេញ ឆ្ពោះទៅរកជាយក្រុង។

១៥នាទី.....គេមកដល់ពីខាងក្រោយអគារចាស់មួយ ជាសំណង់មិនទាន់ហើយ ដែលពេញដោយស្រមោលខ្មៅនៃស្បៃរាត្រី១២រោច។ បេះដូងរបស់គាត់នៅតែលោតញាប់ ប៉ុន្តែពុំមែនខ្លាចមានអ្នកមកតាមទេ ពួកនោះបាត់ស្រមោលហើយ។ ប្រុសស្អាតដកដង្ហើមវែងៗព្រោះកំពុងបង្ខំខ្លួនឯងឱ្យស្ងប់ កុំទៅបញ្ចេញកំហឹងលើដារីន....តែប៉ុណ្ណោះ។

ប្រុសដើរយឺតៗ....ឈប់អាចង្រៃ!

នេះជាអ្វីមួយលើសពីការត្រៀម....កាណុងមួយកំពុងជាប់លើកញ្ចឹងកគេ។

«ដើរ!»

មនុស្សនោះគ្រហឹមបញ្ជា។

ស៊ីណានញញឹម ខណៈដែលចុងកាំភ្លើងនៅត្រជាក់នឹងថ្កល់រុញមកបន្ថែម។

មនុស្សមិនស្គាល់មុខ បង្ខំគេដើរហួសពីរថយន្តកាត់តាមផ្លូវងងឹត។

«ទៅ!»

ចិត្តគេនឹកដល់ដារីនទៀត។

«នាងគិតថា អាចបញ្ចប់ខ្ញុំងាយ?»

គេសួរខ្លួនឯងជាមួយដកដង្ហើមចេញយឺតៗ គំនិតរបស់គេ គឺជះកំហឹងរកនាងរាល់ពេលគេពិបាកស្អុតស្អាញ។ ដាវីនគឺជាគន្លឹះនៃអ្វីៗគ្រប់យ៉ាងក្នុងពេលនេះ។ គេមាននាងក្នុងដៃ គេនឹងឈ្នះ...

«បាញ់ទៅពួកអាកូនឆ្កែម្រើ!»

តាំងពីម្ដាយគេចូលComa គេមិនដែលគិតថា ខ្លួនឯងនៅរស់ទេ។ ជីវិតនេះ មានឬគ្មានស៊ីណានដែលខ្វល់?

អ្នកភ្ជង់មិនមាត់បានបណ្ដើរគេដល់ពីក្រោយសំណង់តែមិនឃើញអ្វីទាំងអស់។ មនុស្សបីនាក់ដដែលតាមមកដល់ ប្រហែលគ្នីគ្នាបានបោះទីតាំងឱ្យ។

ពួកគេមកព័ទ្ធស៊ីណានជុំជិត។

«ឯណាអ្នកនាងតូច!»

ម្នាក់នៅពីមុខគេដើរមកជាមួយទឹកមុខមាំ។ ដ្បិតធ្វើការឱ្យប៉ានាងជាងមួយឆ្នាំ គេមិនដែលឃើញពួកនេះទេ។ បានន័យថា លោកម៉ែនដា នៅពីមុខមហាជនធ្វើជារកស៊ីត្រឹមត្រូវ ក្រោយរាំងនន មានជនពាលនៅបម្រើការទៀត។

គេញញឹមញាក់ស្មាដាក់។

«បាញ់ទៅ!»

មនុស្សនៅមុខគេដែលទំនងជាមេគ្រហឹមលើកដៃមកប្រុងតែដាល់មាត់គេផ្ទង។ តែត្រូវអ្នកភ្ជង់ស៊ីណានគំហក ហើយលើកទូរសព្ទបង្ហាញ។

ពួកគេគោរព។

ក្នុងវីដេអូ គឺម៉ែនដា មនុស្សដែលបេះដូងអ្នកចាប់ជម្រិតឃើញកាលណាឈឺសែនឈឺ។

«កូនអញ!» ម៉ែនដាសួរខ្លី។

ស៊ីណានញញឹម។

«អ្ហែងយកដាវីនទៅណា?!»

«បើខ្ញុំលែងទៅវិញ នាងនឹងស្លាប់!» គេនិយាយមួយៗ។

អ្នកភ្នង់បានគំហកៈ

«ស្អី?»

ហើយរុញកាណុងបន្ថែម ដោយស្មានថាស៊ីណានព្រឺ។ តែអ្នកព្រឺពិតប្រាកដគឺប៉ារបស់ដារីន។

«កូនអញនៅឯណាអារោគចិត្ត?»

«នៅជាមួយគ្រាប់បែក!» គេឆ្លើយត្រជាក់ៗ ញាក់ចិញ្ចើមដាក់លោកកុង្សីយ៍ «ប្រហែល១៥នាទីទៀតអាចផ្ទុះ»។

គ្រប់គ្នាឃើញរាងកាយអភិជនម៉ែនដាញាក់ ព្រោះសម្ដីនេះ។

«អាកុហកអើយ!» អ្នកភ្នង់គំហក។ ស្រាប់តែបទបញ្ជាលាន់មក....។

«លែងវា!»

ម៉ែនដាប្រហែលដឹងថា យប់នេះគេយកស៊ីណានមកធ្វើស៊ីមិនបានតាមគម្រោងទេ។ គាត់មិនអាចទទួលយកបានឡើយបើឱ្យដារីនស្លាប់ក្នុងវ័យប៉ុណ្ណេះ។

ឯងចង់បានលុយប៉ុន្មាន?

គ្មានចម្លើយ។ ស៊ីណានញញឹមពេលកាណុងដកចេញពីគល់ក។

ចិត្តគេ គឺយកនាងទៅធ្វើឲ្យឪពុកនាងរងទុក្ខ នាំលោកម៉ែនដា មកលុតជង្គង់សូមទោសម្ដាយគេ។ ប៉ុន្តែមិនមែនឥឡូវនេះទេ។ គេត្រូវការឱ្យគ្រួសារនេះស្គាល់ជីវិតដែលមានសម្ពាធ ដកដង្ហើមមិនរួច ហើយគេងមិនលក់ ឆីមិនឆ្ងាញ់។

ទោះយ៉ាងណា ពេលត្រូវលែងចេញមកភ្លាមៗ គេចាប់ផ្ដើមមកមករកកន្លែងដែលគេលាក់ស្រីទាំងប្រាកដថា គ្មានអ្នកតាមមកទេ។

តាមផ្លូវប្រុសមានអារម្មណ៍ថា ផែនការនេះផុយស្រួយពេក ប្រចុយប្រចានពេក ត្រូវប្ដូរសេណារីយ៉ូខ្លះ ទើបអាចធ្វើទុក្ខបុកម្នេញម៉ែនដាបានយូរ។

ភ្នែករបស់ស៊ីណានរួមតូច ពេលគេកាច់ចង្កូតឡាន ហើយគិតដល់ល្បិចថ្មី។

ប្រសិនចង់ឱ្យប៉ានាងទៅសុំទោសម៉ាក់គេនិងសារភាពគ្រប់យ៉ាងដើរចូលគុក ការចាប់ពង្រត់ធីតារបស់គ្រួសារនេះ មិនគ្រប់គ្រាន់នៅឡើយទេ។

ការចាប់ដាវីនធ្វើបាប ដល់នាងស្លាប់ទៀត ក៏សម្រាលការឈឺចាប់ព្រោះមនុស្សស្លាប់គឺចប់ តែទុកនាងជាឈ្លើយពេញមួយជីវិតប្រហែលជាទណ្ឌកម្មល្អជាង។

មានដំណោះស្រាយហើយ....។ ខណៈដែលស៊ីណានគោលដៅ គេរវៃភ្នែកមើលគ្រប់យ៉ាង ហើយទើបបានបញ្ជារថយន្តចូលទៅក្នុងយានដ្ឋាននៃផ្ទះល្វែងលាក់ខ្លួនរបស់គេ។

នេះជាផ្ទះចាស់របស់ជីតាខាងម្តាយគេទុកមកឱ្យ។

បើកាលណោះម៉ែនដាដឹង ប្រហែលសូម្បីដីនេះនិងផ្ទះនេះក៏យកទៅអស់ដែរ ប្រុសស្អាតគិតទាំងចិត្តសែនស្អប់ខ្ពើម។

គេឈានឡើង ហើយងាកមកសម្លឹងបន្ទប់ដែលនាង....កំពុងនៅ។

ប្រុសញញឹមបានចិត្ត ហើយញាក់ស្មាបន្តិចមុនពេលលើកសោមកចាក់ ហើយដៃរុញទ្វារ។ ក្នុងបន្ទប់មិនឃើញនាងទេ។

ស្នូរទឹកបើកក្នុងបន្ទប់ទឹក....ម្ចាស់ផ្ទះជ្រួញចិញ្ចើមគិត។

ងូតទឹកថ្មើរហ្នឹង?

លេងល្បិច?

ប្រុសញញឹមហើយរុញទ្វារចូល។

ជាប់គាំងព្រោះចាក់គន្លឹះ។

គេខាំមាត់និយាយតិចៗ៖

«ងូតទឹកជិតភ្លឺ?»

គ្មានចម្លើយ។

«បើកទ្វារ?» គេគំហក។

គ្មានចម្លើយដដែល។

ជាមួយកំហឹងនិងចម្ងល់ គេគិតថានាងលួចរត់ដោយធ្វើលេសបើកទឹកចោល?

បុរសបើកសោភ្លាម ក្រាក.....

រាងកាយអាក្រាតកំពុងឈរពីចំហៀង ត្រងយកតំណក់ទឹកយ៉ាងមានសុភមង្គល។

គេឈរភាំង....ខណៈរាងកាយកម្រើកអារម្មណ៍ក្តៅៗ......។ មិនដែលគិតថា ចំណាប់ខ្មាំងនឹងមានឈុតឆាកបែបនេះជាមួយគេទេ។

«នាងលេងល្បិច?» គេប្រាប់ខ្លួនឯង។

វ៉ាស!

ស្រីស្អាតងាកមក ហើយស្រែកអស់មួយទំហឹង។ ទាញអារម្មណ៍ខាងប្រុសទម្លាក់មកកន្លែងដើមវិញគ្រាកំពុងហោះហើរទៅរកអាកាសវេហា។

នាងទាញកន្សែងមករញីរញ័រ....គេមិនដកភ្នែកចេញពីរូបរាងទេពអប្សរបានទោះចិត្តគេចង់ តែភ្នែកគេទាមទារនៅ។ ដើមទ្រូងងរ ចង្កេះ ពោះរាបស្មើ សាច់រលោងស្រអែមក្រហម ភ្លៅរលូន សក់គ្របដល់ខ្នងខ្មៅក្រឹប។

«ថ្មើរហ្នឹងងូតទឹក?»

គេរអ៊ូរង៉ូវៗដើម្បីបំភាន់កាមតណ្ហា។

«មនុស្សឆ្កួត! រោគចិត្ត! ចូលមកធ្វើអី?»

ពាក្យជេររបស់នាង«រោគចិត្ត» ធ្វើឱ្យគេនឹកឃើញភ្លាមដល់សម្តីឪពុកនាងមុននេះ....ក្តៅៗ។ ដាវីនកំពុងពាក់កណ្តាលអាក្រាត នាងគួរដឹងថា នាងកំពុងនៅកន្លែងណា ម្តេចសម្តីនាងថ្លោះដូចប៉ានាងម្ល៉េះ?

ដោយមិនព្រាងទុក មនុស្សប្រុសមុខមាំនិងស្លេកជាមួយរំងើកភ្លើងសត្វលោក រំសៀកខ្លួនចូលមកដល់។ នាងគាំងថយក្រោយ ខណៈដៃឆ្វេងរឹងមាំរបស់គេរាំងនាងមិនឱ្យចេញបាន។

ទីនេះចង្អៀត តែមិនចង្អៀតដូចរបៀបគេកំពុងសម្លឹងសម្លក់ភ្នែកនាងទេ។

«ចេញ!» ស្រីនិយាយញ័រៗ ដៃនាងទាំងពីរក្តោបកន្សែង។

នាងយំហើមភ្នែក ទើបតែដាច់ចិត្តហ៊ានមកងូតទឹកព្រោះគិតថា យប់ជ្រៅពេកហើយ មនុស្សអាក្រក់របស់នាងដេកលក់បាត់ហើយ នាងមានឱកាសមកសម្អាតខ្លួនម្តង។ ដឹងអីពេលនេះ ទើបភ្ញាក់ខ្លួនថា គេនេះមានសិទ្ធិគ្រប់យ៉ាងមិនថាថ្មើរម៉ោន នៅកន្លែងណា ជាមួយនាង ព្រោះនេះនាងកំពុងជាចំណីព្យួរកកចោលក្នុងទូទឹកកករបស់គេ យ៉ាងឈឺចាប់ គេចង់មកយាយីនាងពេលណាក៏បាន។

ស្រមៃមើលថា ខ្លួនប្រុសអាយុជាងម្ភៃ ឡើងកម្លាំងរឹងរូសបែបណា ពេលមកឃើញនាងរបៀបនេះថ្មីរណោះ ក្នុងកាលៈទេសៈបែបនេះ។

ទឹកក្ដៅអ៊ុនៗពីក្បាលផ្កាឈូកស្រោចស្រពមកលើពួកគេ តែគេនៅធ្មឹងមើលភ្នែកនាងមិនស្រកស្រុតកំហឹងឡើយ។ កំហឹងតណ្ហាឬកំហឹងរឿងចាស់ៗរវាងគ្រួសារនិងគ្រួសារ មិនដឹងទេ ដឹងតែថាភ្នែកគេ កំពុងបំភ័យនាងយ៉ាងខ្លាំង។

«ឮទេ! ចេញពីខ្ញុំ!» នាងរអ៊ូៗទាំងញាប់ញ័រ។

«បញ្ជាអ្នកណា? អ្ហះ គិតថាខ្លួនឯងជាអ្នកណា?»

គេគ្រហឹមហើយសួរនាងក្ងួរៗព្រោះនៅជិតគ្នាពេក។ គេមិនបាច់បញ្ចេញសម្រែកឬការសម្លុតទេ តែនាងស្លុតស្រេចទៅហើយ។

ដារីនងាកបែបណាក៏គ្មានចន្លោះរើចេញពីភ្នែកមនុស្សនេះដែរ។ បបូរមាត់នាងញាប់ញ័រ គ្មានសម្ដី តែភ្នែកនាងអង្វរករយ៉ាងភ័យខ្លាច។

ខ្យល់ព្យុះនៅក្នុងទ្រូងប្រុសប្រាណមិនបានស្ងប់ស្ងាត់ងាយទេ ដៃស្ដាំគេទម្លាក់ភ្លឹបមកលើចង្កេះនាង។ ស្រីបិទភ្នែកស្រែកយ៉ៃ។

ដៃគេបានរញ៉េរញ៉ៃនៅកន្លែងនោះ ហើយរេមកក្រោយ....ទាមទារសិទ្ធិលើត្រគាករលោងរបស់នាង។